# ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី០៧ ខែមិនា ឆ្នាំ២០១៤

## ជប៉ុនផ្តល់ ៣៤៨,៣៥៨ ដុល្លារអាមេរិកសម្រាប់ គម្រោងសន្តិសុខស្បៀង និងអាហារូបត្ថម្ភក្នុងខេត្តកំពង់ឆ្នាំង



ក្រោមគ្រោងការណ៍ នៃជំនួយឧបត្ថម្ភឥតសំណងសម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន រដ្ឋាភិបាលជប៉ុនបានផ្តល់ទឹកប្រាក់សរុបចំនួន ￥២៨,៥៦៥,៣៥៦ ប្រមាណជា ៣៤៨,៣៥៨ ដុល្លាអាមេរិក ដល់មូលនិធិសម្រាប់ការអភិវឌ្ឍន៍ និងជំនួយសង្គ្រោះអន្តរជាតិ(FIDR)។ កិច្ចសន្យាផ្តល់ជំនួយត្រូវបានចុះហត្ថលេខានាថ្ងៃនេះដោយឯកឧត្តម គូម៉ាម៉ារ៉ូ យូជិ ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និងលោកស្រី អាកេមិ តាកាហាហ្ស៊ិ(TAKAHASHI Akemi) នាយិកាFIDR នៅស្ថានទូតជប៉ុន សម្រាប់គម្រោងសន្តិសុខស្បៀង និងអាហារូបត្ថម្ភក្នុងខេត្តកំពង់ឆ្នាំង។



ដើម្បីបង្កើនទិន្នផលនៃផលិតកម្មស្រូវ និងកែលម្អពិពិធកម្មក្នុងវិស័យកសិកម្មនៅស្រុករលាប្អៀរ និងស្រុកបរិបូរណ៍ ខេត្តកំពង់ឆ្នាំង FIDRនឹងផ្តល់វគ្គបណ្តុះបណ្តាល និងសិក្ខាសាលាដល់ប្រជាជនចំនួន ៥,៨៥៧ គ្រួសារ។ ជាមួយជំនួយបច្ចេកទេសពីFIDR ប្រជាជនមូលដ្ឋានប្រមាណ២៥,៦០០នាក់ក៏នឹងអាចទទួលបានចំណេះដឹងពាក់ព័ន្ធនឹងអនាម័យនិងអាហារូបត្ថម្ភផងដែរ។ ពួកគេនឹងទទួលបានអត្ថប្រយោជន៍ពីការកែលម្អលក្ខខ័ណ្ឌសុខភាព និងអាហារូបត្ថម្ភ។ គោលបំណងសំខាន់នៃគម្រោងនេះគឺដើម្បីកាត់បន្ថយភាពក្រីក្រ និងធានាសន្តិសុខស្បៀង និងអាហារូបត្ថម្ភដល់ភូមិចំនួន៣៩នៃឃុំចំនួន៥។

កម្មវិធីជំនួយឥតសំណងសម្រាប់គម្រោងអង្គការក្រៅរដ្ឋាភិបាលជប៉ុនត្រូវបានចាប់ផ្តើមនៅប្រទេសកម្ពុជាតាំងពីឆ្នាំ២០០២ដើម្បីគាំទ្រដល់សកម្មភាពរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុនក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីជួយដល់ការអភិវឌ្ឍន៍ និងស្តាបនាប្រទេសកម្ពុជាឡើងវិញនៅតាមកំរិតមូលដ្ឋាន។ ចាប់តាំងពីឆ្នាំ២០០២មក រដ្ឋាភិបាលជប៉ុនបានផ្តល់ថវិកាជាង ២០.១ លានដុល្លាអាមេរិកដល់គម្រោងចំនួន ៧៦ គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុនដែលផ្តោតសំខាន់ទៅលើវិស័យអប់រំនៅកម្រិតមូលដ្ឋាន វិស័យសុខាភិបាល និង សកម្មភាពបោសសំអាតមីន។ គម្រោងរបស់មូលនិធិសម្រាប់ការអភិវឌ្ឍន៍ និង ជំនួយសង្គ្រោះអន្តរជាតិ(FIDR) នេះគឺជាគម្រោងទី៦ តាមរយៈគ្រោងការណ៍នៃជំនួយនេះសម្រាប់ឆ្នាំសារពើពន្ធឆ្នាំ ២០១៣ របស់ប្រទេសជប៉ុន (មេសា២០១៣ ដល់ មិនា២០១៤)។



---


*ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា*

*ទូរស័ព្ទ: ០២៣-២១៧-១៦១ ទូរសារ: ០២៣-២១៤-៣៣០*

*អ៊ីមែល: eco.jpn@pp.mofa.go.jp*

*គេហទំព័រ: http://www.kh.emb-japan.go.jp*